នស/រកត/០១១៨/ ០៣៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** អនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរដោយគ្មានការបង្ខិតបង្ខំដល់ **អ្នកស្រី ភាព សុភាន់ "PHEAP SOPHORN"** ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៨០ ទីកន្លែងកំណើត ភូមិទី ០៣ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម ដែលបច្ចុប្បន្នកំពុងរស់នៅសាធារណរដ្ឋចិន។

**មាត្រា ២ ៖** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារល.១៨០១.០៣៩

លេខ: ៦៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃចន្ទ ១៤កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨*